Australian Government

Job Services Australia™

people • skills • jobs

# Work Experience: Work for the Dole

**ការងារដើម្បីទទួលប្រាក់ជំនួយ (Work for the Dole) នឹងផ្តល់ឱកាសដល់លោកអ្នកដើម្បីបណ្តុះជំនាញ និងទទួលបានបទពិសោធន៍ការងារ តាមរយៈសកម្មភាពទាំងឡាយដែលផ្តល់ផលប្រយោជន៍ដល់សហគមន៍តាមតំបន់នៅពាសពេញប្រទេសអូស្ត្រាលី។**

សកម្មភាព Work For the Dole មានជូននៅអង្គការមិនស្វែងរកប្រាក់ចំណេញ និងអង្គការសហគមន៍ ឬអង្គការ និងស្ថាប័នរដ្ឋាភិបាលអូស្ត្រាលីនៅតាមតំបន់ តាមរដ្ឋ និងដែនដី។

អ្នកចូលរួមទាំងអស់ក្នុងសកម្មភាព Work for the Dole ត្រូវទទួលការបណ្តុះបណ្តាលហ្វឹកហ្វឺនដោយមានការរៀបចំត្រឹមត្រូវ តាមកាលៈទេសៈសមស្រប និងប្រសិនបើអាចធ្វើបាន។

លោកអ្នកក៏អាចចូលរួមផងដែរ នៅអំឡុងពេលដែលសមស្របជាមួយនឹងកាតព្វកិច្ចផ្សេងៗរបស់លោកអ្នក ដូចជា ការសិក្សា ការងារមិនពេញលេញ ឬមិនទៀងទាត់ ឬបន្ទុកចិញ្ចឹមបីបាច់កូន។

ការធ្វើការងារ Work for the Dole អាចឱ្យលោកអ្នកធ្វើការជាផ្នែកមួយនៃសកម្មភាពជាក្រុមជាមួយអ្នកស្វែងរកការងារធ្វើផ្សេងៗ ឬធ្វើការម្នាក់ឯងអាស្រ័យលើស្ថាប័នទទួលអ្នកឲ្យធ្វើការងារ (ដូចជាក្រុមសហគមន៍ ឬក្រុមសប្បុរសធម៌)។

ប្រភេទកិច្ចការដែលលោកអ្នកអាចធ្វើជាមួយ Work for the Dole មានលក្ខណៈខុសគ្នា ប៉ុន្តែអាចរួមទាំងឱកាសអភិវឌ្ឍជំនាញ លើផ្នែក៖

- កុំព្យូទ័រ
- ការិយាល័យ ឬលក់ទំនិញរាយ
- សេវាបម្រើអតិថិជន
- រៀបចំប្លង់លម្អតាមសួនច្បារ ឬការងារសម្អាតថែសួន
- ការងារជាងឈើ ការលាបថ្នាំ ការតុបតែងរចនា ការងារជាងដែក ឬការងារធ្វើតេស្តអគ្គិសនី
- ការថែទាំយានជំនិះ និងអគារ
- ជួសជុលអគារប្រវត្តិសាស្ត្រ និងយានជំនិះ
- បដិសណ្ឋារកិច្ច រួមទាំងការរៀបចំចំណីអាហារ
- ជួយសមាជិកក្នុងសហគមន៍ ដូចជា ជនចាស់ជរា ជនពិការ ឬកុមារ (លោកអ្នកប្រហែលត្រូវឲ្យសមត្ថកិច្ចបញ្ជាក់ពីប្រវត្តិគ្មានឧក្រិដ្ឋកម្ម មុននឹងធ្វើការក្នុងកន្លែងថែទាំមនុស្សចាស់ ឬធ្វើការជាមួយកុមារ)។
- ធ្វើកំណត់ត្រាប្រវត្តិសាស្ត្រតាមតំបន់
- ផលិតវីដេអូ គេហទំព័រ ឬសម្ភារៈផ្សព្វផ្សាយ

សកម្មភាព ដែលមានសម្រាប់លោកអ្នក នឹងមានលក្ខណៈខុសគ្នានៅក្នុងស្ថាប័នផ្តល់សេវារកការងារអូស្ត្រាលីនីមួយៗ ហើយអាចមានរួមបញ្ចូលជម្រើសបន្ថែមពីលើសកម្មភាពរៀបរាប់ខាងលើ។

ស្ថាប័នផ្តល់សេវាការងារអូស្ត្រាលី (Job Services Australia) ត្រូវធានាឲ្យប្រាកដថា សកម្មភាព Work for the Dole ៖

- ពង្រីកនូវឱកាសក្នុងការស្វែងរកការងារដល់អ្នកស្វែងរកការងារធ្វើ
- ផ្តល់ឱកាសឱ្យអ្នកស្វែងរកការងារធ្វើទទួលបានបទពិសោធន៍ការងារដែលងាយប្រែប្រួលតាមស្ថានភាព ដើម្បីជួយឱ្យអ្នកទាំងនោះរក្សាទំនាក់ទំនងក្នុងសហគមន៍ និងកន្លែងធ្វើការរបស់ខ្លួន។
- ផ្តល់ឱកាសឱ្យអ្នកចូលរួមទាំងអស់បានចូលរួមក្នុងការបណ្តុះបណ្តាលហ្វឹកហ្វឺនដែលមានការរៀបចំ តាមកាលៈទេសៈសមរម្យ និងប្រសិនបើអាចធ្វើបាន។
- ផ្តល់បទពិសោធន៍ការងារដែលនឹងអភិវឌ្ឍ ឬបង្កើនសមត្ថភាពរបស់អ្នកស្វែងរកការងារធ្វើ ដើម្បីធ្វើការជាក្រុម ទទួលបានការដឹកនាំពីអ្នកត្រួតពិនិត្យ ធ្វើការដោយឯករាជ្យ ចេះប្រាស្រ័យទាក់ទងយ៉ាងល្អ និងជំរុញឲ្យមានទឹកចិត្តថែមទៀតក្នុងការបំពេញការងារ និងពង្រីកភាពជាម្ចាស់ការលើការងារ។
- ស្វែងរកការចូលរួមក្នុងសហគមន៍តាមមូលដ្ឋានតាមរយៈសកម្មភាពដែលនឹងហុចផលប្រយោជន៍ដល់សហគមន៍។

## ការធ្វើការងារ Work for the Dole ពេញពេល

ក្នុងនាមជាអ្នកស្វែងរកការងារធ្វើ លោកអ្នកអាចចូលរួមក្នុងការងារ Work for the Dole ឬធ្វើការពេញពេលជាមួយ Work for the Dole តែម្តង។ សកម្មភាពទាំងនេះ ប្រហាក់ប្រហែលគ្នា ហើយលោកអ្នកអាចធ្វើកិច្ចការប្រភេទដូចគ្នាដោយមិនប្រកាន់ថាលោកអ្នកកំពុងចូលរួមក្នុងការងារជាមួយ Work for the Dole ឬធ្វើការ Work for the Dole ពេញពេលទ្បើយ។ ភាពខុសគ្នាចម្បងនោះគឺចំនួនម៉ោងចូលរួមសរុប។

ការធ្វើការពេញពេលជាមួយ Work for the Dole គឺជាទម្រង់សកម្មខ្លាំងក្លានៃការងារ Work for the Dole។ ជាទូទៅ ការចូលរួម Work for the Dole ពេញម៉ោង និងមានរយៈពេល ២៥ម៉ោងក្នុង ១សប្តាហ៍ សម្រាប់រយៈពេល ១០ខែ ហើយជាធម្មតា Work for the Dole មានរួមបញ្ចូលសកម្មភាពការងារលើសពីមួយ។

ប្រសិនបើលោកអ្នកមានអាយុចន្លោះពី ១៨ទៅ៥៩ឆ្នាំ លោកអ្នកអាចត្រូវចូលរួម Work for the Dole ពេញពេល ប្រសិនបើស្ថាប័នផ្តល់សេវាការងារអូស្ត្រាលីរបស់លោកអ្នកគិតថា លោកអ្នកអាចទទួលបានផលប្រយោជន៍ពីសកម្មភាពសកម្មខ្លាំងក្លា។

6FS09446JSA/khmer

## អ្នកណាអាចចូលរួមបាន?

ប្រសិនបើលោកអ្នកចុះឈ្មោះជាមួយស្ថាប័នផ្តល់សេវាការងារអូស្ត្រាលីណាមួយ លោកអ្នកអាចស្ម័គ្រចិត្តចូលរួម Work for the Dole នៅពេលណាក៏បាន បើលោកអ្នក និងស្ថាប័នផ្តល់សេវាយល់ស្របថាការចូលរួមនេះនឹងផ្តល់ផលប្រយោជន៍ដល់លោកអ្នក។

ប្រសិនបើលោកអ្នកជាអ្នកស្វែងរកការងារធ្វើ ដែលត្រូវមានសកម្មភាពបទពិសោធន៍ការងារ (Work Experience Activity Requirement) លោកអ្នកអាចបំពេញតម្រូវការបែបនេះបាន ដោយការចូលរួមសកម្មភាព Work for the Dole។

ប្រសិនបើលោកអ្នកជាអ្នកស្វែងរកការងារធ្វើដែលត្រូវមានសកម្មភាពខ្លាំងក្លា (Intensive Activity) ឬសកម្មភាពប្រតិបត្តិ (Compliance Activity) លោកអ្នកអាចបំពេញតម្រូវការនេះ តាមរយៈការចូលរួមសកម្មភាព Work for the Dole។ ស្ថាប័នផ្តល់សេវាការងារអូស្ត្រាលីរបស់លោកអ្នកនឹងផ្តល់ឱវាទដល់លោកអ្នក ថាតើលោកអ្នកត្រូវបំពេញ Intensive Activity ឬ Compliance Activity ឬក៏យ៉ាងណា។

ប្រសិនបើលោកអ្នកទទួលបានជំនួយទ្រទ្រង់ប្រាក់ចំណូល ហើយចូលរួមសកម្មភាពជាមួយ Work for the Dole ដោយរួមទាំង ការចូលរួម Work for the Dole ពេញពេល លោកអ្នកនឹងមានសិទ្ធិទទួលបានប្រាក់បន្ថែម $20.80 សម្រាប់រយៈពេល២អាទិត្យម្តង ដើម្បីសម្រាលបន្ទុកថ្លៃចូលរួម។

## របៀបដាក់ពាក្យសុំ

ប្រសិនបើលោកអ្នកមានចំណាប់អារម្មណ៍ក្នុងការចូលរួមសកម្មភាព Work for the Dole សម្រាប់ Work Experience Activity Requirement របស់លោកអ្នក សូមពិភាក្សាជាមួយស្ថាប័នផ្តល់ Job Services Australia របស់លោកអ្នក។

## ភារកិច្ចរបស់លោកអ្នក

ប្រសិនបើលោកអ្នកទទួល Newstart , ប្រាក់ឧបត្ថម្ភយុវជន (Youth Allowance) ឬប្រាក់ជំនួយសម្រាប់ចិញ្ចឹមកូន (Parenting Payment) ដោយមានការតម្រូវឲ្យចូលរួម លោកអ្នកនឹងត្រូវស្វែងរកការងារ ហើយចូលរួមក្នុងសកម្មភាព ដែលនឹងជួយឱ្យលោកអ្នកបានទទួលការងារធ្វើ។

ស្ថាប័នផ្តល់ Job Services Australia នឹងពិចារណាអំពីស្ថានភាពរបស់លោកអ្នកផ្ទាល់ ហើយចរចាអំពីសកម្មភាពសមរម្យ ដើម្បីដាក់បញ្ចូលក្នុងផែនការរកការងារធ្វើ (Employment Pathway Plan) របស់លោកអ្នក។

ប្រសិនបើលោកអ្នកមិនអាចចូលរួមក្នុងសកម្មភាពទាំងនេះបានទេ លោកអ្នកគួរពិភាក្សាជាមួយស្ថាប័នផ្តល់សេវារបស់លោកអ្នក។ ប្រសិនបើលោកអ្នកខកខានមិនបានអនុវត្តសកម្មភាពដែលបានព្រមព្រៀងនោះ ការខកខាននេះអាចប៉ះពាល់ដល់ប្រាក់ជំនួយទ្រទ្រង់ប្រាក់ចំណូលរបស់លោកអ្នក។

## សិទ្ធិឯកជនរបស់លោកអ្នក

ព័ត៌មានផ្ទាល់ខ្លួនរបស់លោកអ្នក ត្រូវបានការពារដោយ *ច្បាប់ឯកជនឆ្នាំ១៩៨៨ (Privacy Act 1988)* ហើយព័ត៌មានអំពីលោកអ្នក អាចត្រូវបានការពារផងដែរដោយ *ច្បាប់ (រដ្ឋបាល) សន្តិសុខសង្គមឆ្នាំ១៩៩៩ (Social Security [Administration] Act 1999)* (ឧទាហរណ៍ ប្រសិនបើលោកអ្នកទទួលប្រាក់ជំនួយទ្រទ្រង់ប្រាក់ចំណូល)។ ព័ត៌មានរបស់លោកអ្នកអាចត្រូវស្ថាប័នផ្តល់ Job Services Australia ព្រមទាំងក្រសួងអប់រំការងារ និងទំនាក់ទំនងកន្លែងធ្វើការ [DEEWR], (Department of Education, Employment and Workplace Relations [DEEWR]) ប្រើប្រាស់រួមគ្នាជាមួយ Centrelink និងក្រសួង ក៏ដូចជាទីភ្នាក់ងាររដ្ឋាភិបាលអូស្ត្រាលីផ្សេងៗទៀត ដើម្បីផ្តល់លទ្ធភាពឱ្យអង្គការទាំងនោះ ផ្តល់ជូនលោកអ្នកនូវសេវាដ៏សមស្របបំផុត ដើម្បីបំពេញតាមតម្រូវការរបស់លោកអ្នក។

ចំពោះព័ត៌មានបន្ថែមអំពីភាពឯកជនរបស់លោកអ្នក សូមសាកសួរស្ថាប័នផ្តល់ Job Services Australia របស់លោកអ្នក DEEWR ឬបើកមើលវ៉ិបសាយថ៍ **privacy.gov.au** ។

## ការធានាផ្តល់ សេវារបស់យើងជូនលោកអ្នក

### ការធានាសេវា

លោកអ្នកនឹងទទួលបានសេវាការងាររៀបចំឡើងសម្រាប់រូបលោកអ្នកផ្ទាល់ដែលផ្តល់ដោយស្ថាប័នផ្តល់ Job Services Australia ។ សេវាទាំងនេះនឹងមានលក្ខណៈបត់បែនទៅតាមស្ថានភាព និងប្រវត្តិការងាររបស់លោកអ្នក។ ដើម្បីមើលពីការធានារបស់សេវាទាំងអស់នេះ សូមចូលទៅវ៉ិបសាយថ៍ **deewr.gov.au/jobservicesaustralia** ។

### ក្រមសីលធម៌វិជ្ជាជីវៈ

ស្ថាប័នផ្តល់ Job Services Australia ចុះកិច្ចសន្យាដើម្បីផ្តល់សេវាការងារដែលឧបត្ថម្ភថវិកាដោយរដ្ឋាភិបាលអូស្ត្រាលី និងបានយល់ព្រម ហើយប្តេជ្ញាប្រតិបត្តិតាមក្រមសីលធម៌វិជ្ជាជីវៈ ក្នុងការផ្តល់សេវាការងារនេះ។ ដើម្បីមើលក្រមសីលធម៌វិជ្ជាជីវៈ សូមចូលទៅវ៉ិបសាយថ៍ **deewr.gov.au/jobservicesaustralia**។

## សម្រាប់ព័ត៌មានបន្ថែម

**សូមទូរស័ព្ទទៅលេខ 13 17 64 ឬបើកមើលវ៉ិបសាយថ៍ deewr.gov.au/jobservicesaustralia ។**